# វេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤២

# ប្រធានបទ "ការគ្រប់គ្រងធនធានមនុស្សក្នុងវិបត្តិសកលកូវីត១៩"

*ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០២១*
*ម៉ោង ៨:៣០ ដល់ ១២:០០ ថ្ងៃត្រង់*
*តាមរយៈប្រព័ន្ធអនឡាញ **ZOOM***

## I. សេចក្តីផ្តើម

វិបត្តិកូវីតសកលបាននឹងកំពុងរីករាលដាលពាសពេញសកលលោក។ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាលក៏បាននិងកំពុងធ្វើការយ៉ាងមមាញឹកទប់ទល់តាមរយៈការប្រើប្រាស់វិធានការណ៍ច្បាប់ បទបញ្ញាតិ និងការជួយសង្គ្រោះផ្សេងៗ។ ទន្ទឹមនឹងនោះផងដែរ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតសកល កូវីត១៩នេះយ៉ាងសកម្មផងដែរ តាមរយៈការអនុវត្តគោលការណ៍ សុខាភិបាល និងវិធានផ្សេងៗ ស្របតាមបទដ្ឋានសុវត្ថិភាព ។យ៉ាងណាក្តី ការរីករាលដាលកូវីតនៅប្រទេសកម្ពុជានៅមិនទាន់មើលឃើញថាមានភាពធូរស្រាលនៅឡើយ។ គិតត្រឹមថ្ងៃ ២៥ កក្កដា កម្ពុជាមានករណីឆ្លងសរុប ៧៣.៧០១ នាក់ ជាសះស្បើយ ៦៥.៩៥០ នាក់ និងស្លាប់ ១.៣០៥ នាក់។

ដើម្បីឆ្លើយតបនឹងតម្រូវការសមាជិករបស់ខ្លួនផង និងចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា **អង្គការ គ.ស.ក** នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី៤២ តាមរយៈប្រព័ន្ធអនឡាញ(ZOOM) ក្រោមប្រធានបទ **ការគ្រប់គ្រងធនធានមនុស្សក្នុងវិបត្តិសកលកូវីត១៩។**

ត្រឹមខែធ្នូ ឆ្នាំ២០២០ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ហៅកាត់ថា (គសក) មានសមាជិកសរុបទាំងអស់ប្រហែលចំនួន ២០០ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុតសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃវេទិការៀនសូត្រ

១. យល់ដឹងបន្ថែមពីតួលេខសកលនៃការរីករាលដាល ជម្ងឺកូវីត១៩ ព្រមទាំងវិធីសាស្ត្រតាមដានព័ត៌មាន

២. យល់ដឹងស្តីពី ច្បាប់ និងបទប្បញ្ញត្តិការពារការរីករាលដាលកូវីត១៩ ដែលចេញដោយរាជរដ្ឋាភិបាល

DRAFT

៣. ចែកចាយ និងរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក ក្នុងការឆ្លើយតបនឹងការរីករាលដាលកូវីត១៩ តាមស្ថាប័នផ្សេងៗ
៤. ទទួលបានការពង្រឹងទឹកចិត្តតាមរយៈវគ្គសិក្សាផ្លូវចិត្តស្តីការពីការទប់ទល់កូវីត១៩ និងការរស់នៅក្នុងបរិបទថ្មី

## III. អ្នកចូលរួមគោលដៅ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស** ដែលអញ្ជើញមកពី **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ក្នុងប្រទេសកម្ពុជា។

## IV. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីទទួលបានតំណរថ្មី (New Link) ពីក្រុមការងារ អង្គការ គសក ក្នុងការចូលរួមវេទិការៀនសូត្រនេះ។ តំណរនឹងផ្ញើជូនអ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌ**មួយថ្ងៃមុនវេទិកា**រៀនសូត្រចាប់ផ្តើម។

## V. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:00-០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | • ក្រុមការងារ គសក |
| ០៨:៣០-០៨:៤០ | - ការណែនាំពីរបៀបប្រើ ZOOM និង បទបញ្ជាផ្ទៃក្នុងវគ្គ<br>- គោលបំណងវេទិការៀនសូត្រ | **លោក លឹម ឌីណា**<br>អ្នកឯកទេសផ្នែកកៀគរធនធាន<br>អង្គការ គ.ស.ក |
| ០៨:៤០-០៨:៥០ | កិច្ចស្វាគមន៍ និងបើកកម្មវិធី | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ០៨:៥០-០៩:០៥ | - **បទបង្ហាញស្តីពីតួលេខសកលស្តីពីការរីករាលដាល កូវីត១៩ ព្រមទាំងវិធីសាស្រ្តតាមដានព័ត៌មាន** | **ហេង រតនា**<br>តំណាងសមាជិកក្រុមការងារ (HR Working Group) |
| ០៩:០៥-០៩:២០ | - **បទបង្ហាញស្តីពីច្បាប់និងគោលការផ្សេងៗ ដែលចេញដោយរាជរដ្ឋាភិបាល** | តំណាងក្រុមការងារ (គសក) |

| | | |
|---|---|---|
| ០៩:២០-១០:២០ | - **វគ្គពិភាក្សាជាក្រុម ស្តីពីបទពិសោធន៍ វិធីសាស្រ្ត និងការឆ្លើយតាមតាមស្ថាប័នផ្សេងៗ** | តំណាងក្រុមការងារ (គសក) និងតំណាងសមាជិកក្រុមការងារ (HR Working Group) |
| ១០:២០-១០:២៥ | សំរាក | |
| ១០:២៥-១១:៥៥ | - **វគ្គសិក្សាផ្លូវចិត្តស្តីការពីការទប់ទល់កូវីត១៩ និងការរស់នៅក្នុងបរិបទថ្មី** | តំណាងអង្គការ TPO |
| ១១:៥៥-១២:00 | បិទកម្មវិធី | **ឡាយ ឈុន**<br>តំណាងសមាជិកក្រុមការងារ (HR Working Group) |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។ វេទិការៀនសូត្រនឹងត្រូវបានថតវីដេអូ សម្រាប់ការរៀបចំរបាយការណ៍។*

DRAFT